មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និង ត្រា

ជា ស៊ីម

៣៖ល.០៤.០៩.០០២៧៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ : ១៨៧ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០០២

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន សារី

ព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សាធម្មនុញ្ញ **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿង

លេខ ០៥៣/០០៧/២០០២

ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០២

សេចក្ដីសំរេច

លេខ ០៤៧/០០២/២០០២ កបធ.ច

ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសេចក្ដីសំរេចលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០ ស្ដីពីការបកស្រាយមាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញទាក់ទងនឹងឃ្លាថា " បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ "
- បានឃើញលិខិតលេខ ៨៣០ រស ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០២ របស់សម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភាស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលរដ្ឋសភាបានអនុម័តយល់ព្រមនៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ក្នុងសម័យប្រជុំរដ្ឋសភាលើកទី ៨ នីតិកាលទី ២
- បានឃើញលិខិតលេខ ៦៨៩/០៩០២/អ.ពស/ន.រ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០២ របស់អគ្គលេខាធិការព្រឹទ្ធសភា

ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី វាក្យខ័ណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នេះត្រូវបានប្រកាសឱ្យប្រើ ។

- យល់ឃើញថា រដ្ឋសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញក្នុងការពិនិត្យ អនុម័តច្បាប់ខាងលើនេះ ។
- យល់ឃើញថា ប្រធានព្រឹទ្ធសភា (ស្តីទី) ដែលបានសរសេរថា ព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យអត្ថបទច្បាប់នេះ ពុំបានបើកសម័យប្រជុំព្រឹទ្ធសភាពេញអង្គដើម្បីអនុម័តសេចក្តីសំរេចយ៉ាងដូចនេះទេ ។ ដូច្នេះ គឺជាសេចក្តីសំរេចឯកតោភាគីផ្ទាល់ខ្លួនរបស់ប្រធានព្រឹទ្ធសភា (ស្តីទី) គឺថាមិនមែនរបស់ព្រឹទ្ធសភាដូចដែលមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញបានតម្រូវនោះឡើយ ។
- យល់ឃើញថា ក្នុងករណីដូចបានលើកឡើងខាងលើនេះ វិធានទាំងឡាយដែលមានចែងក្នុងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីការបកស្រាយមាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញទាក់ទងនឹងឃ្លាថា " បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ " ក៏មិនត្រូវបានអនុវត្តតាមដែរ ។
- យល់ឃើញថា ការគោរពនីតិវិធីដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ជាការចាំបាច់សំរាប់តម្រូវការនៃនីត្យានុកូលភាព ដែលចាប់ពីពេលនេះតទៅមិនគួរឱ្យមានការខ្វះខាតទៀតឡើយ ។
- យល់ឃើញថា ទំរង់នៃការតាក់តែង និងអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។
- យល់ឃើញថា ខ្លឹមសារមាត្រាទាំងពីរនៃច្បាប់នេះក៏ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

សំរេច

មាត្រា ១ : យោងតាមមូលបទខាងលើ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសំរេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២

ខ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ ០៥៣/០០៦/២០០២

ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០២

សេចក្ដីសំរេច

លេខ ០៤៨/០០៣/២០០២ កបធ.ច

ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ១៣៤ / ០៨០២ / ពស / ក្រ.ច ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ របស់ព្រះអង្គម្ចាស់ស្ដេចក្រុមឃុន **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស** ប្រធានព្រឹទ្ធសភាស្ដីទីស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ " មាត្រា ១០១ ថ្មី " និងពាក្យ "ការបោះឆ្នោតអសកល " ដែលមានប្រើក្នុងមាត្រា ៩៩ថ្មី និងមាត្រា ១០០ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០២

ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍
ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា តាមមាត្រា ១៣៦ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៥ នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ពាក្យបណ្ដឹងរបស់ស្ដេចក្រុមឃុន **ស៊ីសុវត្ថិ ជីវ័នមុនីរក្ស** ប្រធានព្រឹទ្ធសភាស្ដីទីខាងលើអាចទទួលយកមកពិចារណាបាន ។

- យល់ឃើញថា ក្នុងមាត្រា ១០១ ថ្មី នៃរដ្ឋធម្មនុញ្ញ ពាក្យដែលគួរពិចារណា និងអាចមានការភ័ន្តច្រឡំ គឺ *អ្នកបោះឆ្នោត អង្គបោះឆ្នោត មណ្ឌលបោះឆ្នោត* ។
- យល់ឃើញថា *អ្នកបោះឆ្នោត* គឺអ្នកដែលមានគ្រប់លក្ខណៈសម្បត្តិតាមច្បាប់កំណត់ ។
- យល់ឃើញថា *អង្គបោះឆ្នោត* គឺជាក្រុមមនុស្សដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចទៅបោះឆ្នោតបានតាមការកំណត់នៃច្បាប់ សំរាប់រើសតំណាងអោយភូមិភាគ ឬតំណាងវិជ្ជាជីវៈនានា ។ ឧទាហរណ៍ ច្បាប់អាចកំណត់ថា ជាក្រុមជនជាតិ ជាក្រុមកសិករ ក្រុមអ្នកនេសាទ ក្រុមពាណិជ្ជករ ក្រុមឧស្សាហករ ក្រុមកម្មករ មន្ត្រីរាជការ និងក្រុមវិជ្ជាជីវៈដទៃទៀត ។ល។
- យល់ឃើញថា *មណ្ឌលបោះឆ្នោត* ជារង្វង់ដែនដីភូមិសាស្ត្រ ដែលច្បាប់កំណត់សំរាប់អង្គបោះឆ្នោត ។ ឧទាហរណ៍ ច្បាប់អាចនឹងកំណត់យកភូមិភាគ ឬខេត្តក្រុង ។ល។ ជាមណ្ឌលបោះឆ្នោត ។
- យល់ឃើញថា *ការបោះឆ្នោតអសកល* ជាការបោះឆ្នោតមិនទូទៅដូចការបោះឆ្នោតសកល ។ ច្បាប់បន្ថែមលក្ខខណ្ឌផ្សេងទៀតដល់អ្នកបោះឆ្នោត លើសពីលក្ខខណ្ឌដែលតំរូវដល់អ្នក-បោះឆ្នោតសកល ។ ឧទាហរណ៍ ដូចជាអ្នកមានសិទ្ធិបោះឆ្នោតក្នុងការបោះឆ្នោតសកលហើយ ប៉ុន្តែត្រូវជាក្រុមកសិករ ក្រុមអ្នកនេសាទ ក្រុមពាណិជ្ជករ ក្រុមឧស្សាហករ ក្រុមកម្មករ មន្ត្រីរាជការ និងក្រុមវិជ្ជាជីវៈដទៃទៀត ។ល។ ថែមទៀត ។ ការបោះឆ្នោតអសកលអាចប្រព្រឹត្តទៅដោយចំពោះ ឬមិនចំពោះ ។

សំរេច

មាត្រា ១ : មាត្រា ១០១ ថ្មី នៃរដ្ឋធម្មនុញ្ញ និងពាក្យ *ការបោះឆ្នោតអសកល* ត្រូវបកស្រាយដូចមានបញ្ជាក់ក្នុងមូលបទខាងលើ ។

មាត្រា ២ : សេចក្តីសំរេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០២

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ
ប្រធាន

ប៊ិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៩២...អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្ដីពីការបែងចែកឥណទានថវិកាចំណាយ តាមជំពូក នៃច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្ដីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ម

<u>***សំរេច***</u>

<u>*មាត្រា១*</u>*: ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ៤.៨១០ លានរៀល (បួនពាន់ប្រាំបីរយដប់លានរៀលគត់) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែក ចំនួន ២.៤១០ លានរៀល (ពីរពាន់បួនរយដប់លានរៀល) និង ពីជំពូក ៤១ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក ចំនួន ២.៤០០ លានរៀល (ពីរពាន់បួនរយលានរៀល) មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការ គ្រប់គ្រងឆ្នាំ ២០០២ ។*

<u>*មាត្រា២*</u>*: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើ ឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយពិសេសរបស់រាជរដ្ឋាភិបាល ។*

<u>*មាត្រា៣*</u>*: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។*

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>***កន្លែងទទួល***</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *កាលប្បវត្តិ - ឯកសារ*

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៩៧...អនក្រ . បក

អនុក្រឹត្យ

ស្តីពីការបង្កើនប្រាក់ម្ហូបអាហារ ជូនកងកំលាំងនគរបាលជាតិ និង មន្ត្រីអនុរក្ស ពន្ធនាគារទូទាំងប្រទេស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ រៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតបង្កើនប្រាក់ម្ហូបដល់កងកំលាំងនគរបាលជាតិ និង មន្ត្រីអនុរក្សពន្ធនាគារ ទូទាំងប្រទេស ចំនួន ៦០០ រៀល (ប្រាំមួយរយរៀលគត់) ក្នុងម្នាក់មួយថ្ងៃ លើចំនួនប្រាក់ដែលកំពុងអនុវត្តបច្ចុប្បន្ន ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ តទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៣៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការអនុវត្តវិន័យមន្ត្រីនគរបាលជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានអនុវត្តវិន័យចំពោះលោកវរសេនីយ៍ឯក ឡឿក សុផាន អត្តលេខ: ០២០៨ ឋានៈអនុប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ នៃក្រសួងមហាផ្ទៃ ក្នុងរូបភាពដកហូតឋានៈ ឋានន្តរសក្តិ និង បណ្តេញចេញផុតពីក្របខណ្ឌមន្ត្រីនគរបាលជាតិ ដោយមូលហេតុ បោះបង់ចោលការងារ ។

មាត្រា ២ : ប្រាក់បៀវត្ស - របបឧបត្ថម្ភផ្សេងៗត្រូវកាត់ចេញពីក្របខណ្ឌនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ចាប់តាំងពីខែ.[illegible] ឆ្នាំ ២០០២ នេះតទៅ ។

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣៣..អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ឈឹម មង្គល** ជាជំនួយការឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើប្រធាននាយកដ្ឋាន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលមានការពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ. កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៤៣៨...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ធំ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៣ រូប នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា នៅឃុំពាមបាង និង បណ្ណាល័យ នៅវិទ្យាល័យរស្មីសោភ័ណ ស្រុកស្ទោង ខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោម ÷

១-លោក	**ហ្វូ**	**ហាត់**	បរិច្ចាគប្រាក់ចំនួន	១២.០០០ USD
២-លោក	**ឈ**	**គីរីសុខន**	បរិច្ចាគប្រាក់ចំនួន	១២.០០០ USD
៣-លោកស្រី	**អ៊ឹង**	**មុនីរត្ន**	បរិច្ចាគប្រាក់ចំនួន	១៣.០០០ USD

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកត/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ស ំ រ េ ច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីរាជការនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដូចមានរាយនាមខាងក្រោម :

១-លោក	**ញាណ**	**ស្រស់**	ជាប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ
២-លោក	**ទូច**	**ហេង**	ជាប្រធាននាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស
៣-លោក	**លី**	**សំអាន**	ជាប្រធាននាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ
៤-លោក	**ត្រាំ**	**សុន្ទរ**	ជាប្រធាននាយកដ្ឋានប្រៃសណីយ៍ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣ " ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៣៧ អនក្រ-បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមសំណូមពរការងារចាំបាច់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រី ០៤ រូប របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដូចមានរាយនាមខាងក្រោម ៖

១_លោក	ម៉ាន់ ចំរើន	ជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
២_លោក	ជួន សុផល	ជាប្រធាននាយកដ្ឋាននីតិកម្មអប់រំ និង បង្ការការពារ
៣_លោកស្រី	អ៊ឹម ស្រ៊ី	ជាប្រធាននាយកដ្ឋានផែនការ និង បណ្តុះបណ្តាល
៤_លោក	មាស វីរិទ្ធ	ជាប្រធានមន្ទីរពិសោធន៍គ្រឿងញៀន

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៤ សសរ

សេចក្តីសម្រេច

ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ទទួល និង ពិភាក្សាការងារជាមួយគណៈប្រតិភូថ្នាក់ដឹកនាំ នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើច្បាប់បង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល .

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

សំរេច

ប្រការ១ : បង្កើតគណៈកម្មការអន្តរក្រសួងមួយដើម្បីទទួល និងពិភាក្សាការងារជាមួយគណៈប្រតិភូជាន់ខ្ពស់ នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ដឹកនាំដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី Thongloun SISOULITH ដែលនឹងអញ្ជើញមកបំពេញទស្សនៈកិច្ចជាផ្លូវការ និងជាមិត្តភាព នៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី ២ ដល់ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០០២ រួមមានសមាសភាពដូចខាង ក្រោម :

១-ឯកឧត្តម	**ស៊ុយ សែម**	រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	ប្រធាន
២-ឯកឧត្តម	**សុខ ស៊ីផាន់ណា**	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	អនុប្រធាន
៣-ឯកឧត្តម	**អ៊ិត ប្រាំង**	រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
៤-ឯកឧត្តម	**ញៀប ម៉ិនឌីន**	រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
៥-ឯកឧត្តម	**ខ្លូត វ៉ាន់ឌី**	អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
៦-លោក	**តាន់ គីមទិន់**	អគ្គនាយកអគ្គិសនីកម្ពុជា	សមាជិក
៧-លោក	**នួន លាន**	ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ថាមពលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
៨-លោក	**ពេជ ប៊ុន្នី**	អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តរជាតិ ក្រសួងពាណិជ្ជកម្ម	សមាជិក
៩-លោក	**សុខ សុភ័ក្ត្រ**	ប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម	សមាជិក
១០-លោក	**អ៊ុយ សុខារាត្ន**	ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេសក្រសួងពាណិជ្ជកម្ម	សមាជិក
១១-លោក	**ម៉ៅ សុវណ្ណា**	ប្រធានការិយាល័យ នៃនាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម	សមាជិក

ប្រការ២ : គណៈកម្មការនេះមានភារកិច្ច ពិភាក្សាលើបញ្ហាពីរគឺ :

១-ការតភ្ជាប់ និងការលក់ថាមពលអគ្គិសនីអោយកម្ពុជា

២-កិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម រវាងប្រទេសទាំងពីរកម្ពុជា-ឡាវ ។

ប្រការ៣ : រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងផែនការ និងឯកឧត្តម អស់លោកដែលមានរាយនាម ក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

__ចម្លងជូន__

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចប្រការ ៣

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥២៥៥ សហវ.

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០០២

ប្រកាសអន្តរក្រសួង
ស្តីពី
ការតែងតាំងវេជ្ជនេយ្យករបុរេប្រទាន
នៅក្រសួងពាណិជ្ជកម្ម
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត / ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០១ / នស / ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ ១១ /នស / ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ នស / រកម / ១២៩៩ / ១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម លេខ នស / រកម / ១២០១ / ១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៣ ស.ហ.វ.ម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរជ្ជទេយ្យបុរេប្រទាន
- បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បច្ចុប្បន្ន

សំរេច

ប្រការ ១ : ត្រូវបានតែងតាំងលោក **សួស សម្បត្តិ** ឋានៈ នាយកខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ជារជ្ជទេយ្យករបុរេប្រទាន នៅអមក្រសួងពាណិជ្ជកម្ម ។

ប្រការ ២: ការតែងតាំង នេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ៣: រាល់សេចក្តីសំរេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនិងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៤: អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ព្រមទាំងលោក សួស សម្បត្តិ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម-ប្រសិទ្ធ

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ៤ "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ៦៦៧ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០២

ប្រកាស
ស្តីពីការផ្ទេរទ្រព្យសម្បត្តិអចលនវត្ថុ

*****

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ខែវិច្ឆិកាឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម
-បានឃើញអនុក្រឹត្យលេខ ៥៤អនក្រ.បក ចុះថ្ងៃទី២២ខែកញ្ញាឆ្នាំ១៩៩៧ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
-បានឃើញការចាំបាច់របស់ក្រសួង

សំរេច

ប្រការ១ : ផ្ទេរការគ្រប់គ្រងទីតាំងផ្ទះមួយល្វែងលេខ១០៩ អឺ០៣ ភូមិ១ឧសភា ឃុំកំពង់កណ្តាល ស្រុកកំពង់បាយ ខេត្តកំពត មានទំហំ ៤ម x ១២ម ជូនទៅនាយកដ្ឋានកាំកុងត្រូលជាអ្នកគ្រប់គ្រងវិញ ដោយផ្តាច់ចេញពីការគ្រប់គ្រងរបស់ មន្ទីរពាណិជ្ជកម្ម ខេត្តកំពត ។

ប្រការ២: មន្ទីរពាណិជ្ជកម្មខេត្តកំពតត្រូវជំរះអចលនវត្ថុខាងលើ ចេញពីបញ្ជីសារពើភណ្ឌរបស់ខ្លួន ព្រមជាមួយនោះ នាយកដ្ឋានកាំកុងត្រូល ក៏ត្រូវកត់ត្រាអចលនវត្ថុខាងលើ ចូលក្នុងបញ្ជីសារពើភណ្ឌរបស់ខ្លួនផងដែរ ។

ប្រការ៣: នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ នាយកដ្ឋានកាំកុងត្រូល និងមន្ទីរ ពាណិជ្ជកម្មខេត្តកំពត ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម_ប្រសិទ្ធ

ចំលងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-សាលាខេត្តកំពត
-ដូចប្រការ៣ "ដើម្បីអនុវត្ត"
-ឯកសារ- កាលប្បវត្តិ

File: Prakas on transfer assets from MoC Kampot to Camcontrol Dept.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ៦៧៣ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០២

ប្រកាស

ស្តីពីការផ្ទេរទ្រព្យសម្បត្តិអចលនវត្ថុ

*****

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ខែវិច្ឆិកាឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤អនក្រ.បក ចុះថ្ងៃទី២២ខែកញ្ញាឆ្នាំ១៩៩៧ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

<u>សំរេច</u>

ប្រការ១ : ផ្ទេរការគ្រប់គ្រងទីតាំងដីនិងឃ្លាំងអូរកែកន្លែង "ឃ្លាំងដែកដំបូលភ្លោះ" ដីមានទំហំ ១៩៣០ម^{២} និងមានសំណង់ឃ្លាំងសង់ពីលើ ទំហំ ២៤ម x ៥៤ម ស្ថិតនៅស្រុក ពាមរក៍ ខេត្តព្រៃវែង ជូនទៅនាយកដ្ឋានកាំកុងត្រូល ជាអ្នកគ្រប់គ្រងវិញ ដោយផ្តាច់ចេញពីការគ្រប់គ្រង របស់មន្ទីរពាណិជ្ជកម្ម ខេត្តព្រៃវែង ។

ប្រការ២: មន្ទីរពាណិជ្ជកម្មខេត្តព្រៃវែង ត្រូវជំរះអចលនវត្ថុខាងលើ ចេញពីបញ្ជីសារពើភណ្ឌរបស់ខ្លួន ព្រមជាមួយនោះ នាយកដ្ឋានកាំកុងត្រូល ក៏ត្រូវកត់ត្រាអចលនវត្ថុខាងលើ ចូលក្នុងបញ្ជីសារពើភណ្ឌរបស់ខ្លួនផងដែរ ។

ប្រការ៣: នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ នាយកដ្ឋានកាំកុងត្រូល និងមន្ទីរ ពាណិជ្ជកម្មខេត្តព្រៃវែង ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម_ប្រសិទ្ធ

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សាលាខេត្តព្រៃវែង
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ

File: Prakas on transfer assets from MoC Prey Veng to Camcontrol Dept.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ២៧៤ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០២

ប្រកាស

ស្តីពីការផ្ទេរទ្រព្យសម្បត្តិអចលនវត្ថុ

*****

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ខែវិច្ឆិកាឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៥៤អនក្រ.បក ចុះថ្ងៃទី២២ខែកញ្ញាឆ្នាំ១៩៩៧ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម

-បានឃើញការចាំបាច់របស់ក្រសួង

<u>សំរេច</u>

ប្រការ១ : ផ្ទេរការគ្រប់គ្រងទីតាំងដីឡូតិ៍មួយកន្លែង(អតីតទីតាំងស្ថានីយ៍ប្រេងឥន្ធនៈ) ស្ថិតនៅភូមិទី១ ឃុំរកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ មានទំហំ ៧៨៤ម^{២} (បណ្ណ័កម្មសិទ្ធិលេខ J_{12} 1359 ចុះថ្ងៃទី០៤មករា ១៩៩៥) ជូនទៅនាយកដ្ឋានកាំកុងត្រូលជាអ្នកគ្រប់គ្រងវិញ ដោយផ្តាច់ចេញពីការគ្រប់គ្រង របស់មន្ទីរពាណិជ្ជកម្ម ខេត្តតាកែវ ។

ប្រការ២: មន្ទីរពាណិជ្ជកម្មខេត្តតាកែវ ត្រូវជំរះអចលនវត្ថុខាងលើ ចេញពីបញ្ជីសារពើភណ្ឌ័របស់ខ្លួន ព្រមជាមួយនោះ នាយកដ្ឋានកាំកុងត្រូល ក៏ត្រូវកត់ត្រាអចលនវត្ថុខាងលើ ចូលក្នុងបញ្ជីសារពើភណ្ឌ័របស់ខ្លួនផងដែរ ។

ប្រការ៣: នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ នាយកដ្ឋានកាំកុងត្រូល និងមន្ទីរ ពាណិជ្ជកម្មខេត្តតាកែវ ត្រូវអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

<u>ចំលងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-សាលាខេត្តតាកែវ

-ដូចប្រការ៣ "ដើម្បីអនុវត្ត"

-ឯកសារ- កាលប្បវត្តិ

File: Prakas on transfer assets from MoC Takeo to Camcontrol Dept.